JS LAND PLC

លេខ ២០២២/EGMMINUTES/០១

កំណត់ហេតុ
ស្តីពី
**សន្និបាតវិសាមញ្ញលើកទីមួយរបស់ក្រុមហ៊ុន JS LAND PLC.**

ក្រុមហ៊ុន JS LAND PLC. (CSX៖ JSL) សូមជម្រាបជូនម្ចាស់ភាគហ៊ុនគ្រប់រូបឲ្យបានជ្រាបថា សន្និបាតវិសាមញ្ញ (EGM) ត្រូវបានប្រារព្ធធ្វើឡើងតាមបែបនិម្មិត ចាប់ពីម៉ោងប្រហែល ០៩:៣០ នាទីព្រឹក រហូតដល់ ម៉ោង ១០:៣០ ព្រឹក នៅថ្ងៃអង្គារ ទី០៦ ខែតុលា ឆ្នាំ២០២២។ ដោយមានសំណើដែលត្រូវអនុម័តដោយម្ចាស់ភាគហ៊ុនដូចខាងក្រោម៖

ប្រធានបទទី១ - ការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និងអភិបាលឯករាជ្យចំនួន ១ រូប។
ប្រធានបទទី២ - ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ("M&A")។

មុនពេលរៀបចំសន្និបាតនៅថ្ងៃនេះ JS Land បានបង្កើតកំណត់ត្រា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ ដូច្នេះម្ចាស់ភាគហ៊ុន ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះម្ចាស់ភាគហ៊ុន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ (កាលបរិច្ឆេទធ្វើកំណត់ត្រា) បានទទួលលិខិតអញ្ជើញតាមរយៈអ៊ីមែល និងតេឡេក្រាម ពីធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ប្រាក់របស់ JSL) ចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២។ (មានភ្ជាប់មកជាមួយនូវលិខិតរបស់ម្ចាស់ភាគហ៊ុនដែលបានចុះបញ្ជី)

EGM បានទទួលម្ចាស់ភាគហ៊ុនចំនួន ១០ រូប ដែលមានសមតុល្យភាគហ៊ុនសរុបចំនួន ២៣.១៤៨.៧៤៩ ស្របតាមកូរ៉ុមចំនួន ៥១% នៃម្ចាស់ភាគហ៊ុន ដែលចាំបាច់សម្រាប់ការបោះឆ្នោត និងការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមហ៊ុនក្នុងការពង្រីកក្រុមប្រឹក្សាភិបាល។

<u>ប្រធានបទទី១ - ការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និងក្រុមប្រឹក្សាភិបាលឯករាជ្យចំនួន ១ រូប</u>

Dato' Jack Yap ជានាយកប្រតិបត្តិ និងប្រធាននាយកប្រតិបត្តិ បានស្នើសុំតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និងអភិបាលឯករាជ្យចំនួន ១ រូប នៅក្នុងក្រុមប្រឹក្សាភិបាល ដូចខាងក្រោម ៖

១. Yap Maow Jun (ក្រុមប្រឹក្សាភិបាល)
២. Yap Teng Wui (ក្រុមប្រឹក្សាភិបាល)
៣. Tang Chat Tong (ក្រុមប្រឹក្សាភិបាល)
៤. Dato Tan Teck Zin (ក្រុមប្រឹក្សាភិបាលឯករាជ្យ)

សំណើនេះត្រូវបានគាំទ្រដោយ ឧកញ៉ា KOY LE SAN នាយកប្រតិបត្តិនៃក្រុមហ៊ុន JS Land Plc.។

ការបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាភិបាលទាំង ៣ រូប និងក្រុមប្រឹក្សាភិបាលឯករាជ្យចំនួន ១ រូប ត្រូវបានធ្វើឡើង។

ក្នុងអំឡុងពេលបោះឆ្នោត ម្ចាស់ភាគហ៊ុនចំនួន ២ រូប (Meng Lee និង Tang Chun Kiu) មិនអាចទទួលបានទម្រង់នៃការបោះឆ្នោតនោះទេ។ ការបោះឆ្នោតរបស់ពួកគេត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ និងត្រូវបានថតទុក។

ការបោះឆ្នោតបានចំណាយពេលប្រហែល ១៥ នាទី។

JS LAND PLC

<u>ប្រធានបទទី២ - ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ("M&A")</u>

ប្រធានបទទី២ សម្រាប់ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ត្រូវបានស្នើឡើងដោយ Dato' Jack Yap។

សំណើនេះត្រូវបានគាំទ្រដោយ Yap Ting Wui។

ក្នុងអំឡុងពេលបោះឆ្នោត ម្ចាស់ភាគហ៊ុនចំនួន ២ រូប (Meng Lee និង Tang Chun Kiu) មិនអាចទទួលបានទម្រង់នៃការបោះឆ្នោតនោះទេ។ ការបោះឆ្នោតរបស់ពួកគេត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ និងត្រូវបានថតទុក។

ការបោះឆ្នោតបានចំណាយពេលប្រហែល ៥ នាទី។

<u>ការប្រកាសលទ្ធផលនៃការបោះឆ្នោត</u>
ការធ្វើតារាងលទ្ធផលនៃការបោះឆ្នោតបានចំណាយពេលប្រហែល ១៥ នាទី។

<u>លទ្ធផលរបស់ប្រធានបទទី១ - ការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និងក្រុមប្រឹក្សាភិបាលឯករាជ្យចំនួន ១ រូប</u>

ម្ចាស់ភាគហ៊ុនភាគច្រើនបានបោះឆ្នោតជូនក្រុមប្រឹក្សាភិបាលទាំងបីរូបបន្ថែមទៀត និងក្រុមប្រឹក្សា-ភិបាលឯករាជ្យមួយរូបបន្ថែមទៀតនោះ។ លទ្ធផលនៃសន្និបាតវិសាមញ្ញរបស់ម្ចាស់ភាគហ៊ុន រួមជាមួយសំឡេងឆ្នោតរបស់ពួកគេត្រូវបានរៀបរាប់នៅខាងក្រោម៖

| ល.រ. | កម្មវត្ថុ | ចំនួនភាគហ៊ុន (គាំទ្រ) | ភាគរយ (គាំទ្រ) | ចំនួនភាគហ៊ុន (ប្រឆាំង) | ភាគរយ (ប្រឆាំង) |
|---|---|---|---|---|---|
| ក | ការបោះឆ្នោត និងការតែងតាំង Yap Maow Jun ជាក្រុមប្រឹក្សាភិបាល | ២៣.១៤៨.៧៤៩,០០ | ១០០% | ០ | ០ |
| ខ | ការបោះឆ្នោត និងការតែងតាំង Yap Ting Wui ជាក្រុមប្រឹក្សាភិបាល | ២៣.១៤៨.៧៤៩,០០ | ១០០% | ០ | ០ |
| គ | ការបោះឆ្នោត និងការតែងតាំង Tang Chat Tong ជាក្រុមប្រឹក្សាភិបាល | ២៣.១៤៨.៧៤៩,០០ | ១០០% | ០ | ០ |
| ឃ | ការបោះឆ្នោត និងការតែងតាំង Dato' Tan Teck Zin ជាក្រុមប្រឹក្សាភិបាលឯករាជ្យ | ២៣.១៤៨.៧៤៩,០០ | ១០០% | ០ | ០ |

(ដោយការណ៍នៃការបោះឆ្នោតតាមប្រព័ន្ធឌីជីថល និងសន្និបាតតាមបែបនិម្មិតត្រូវបានថតទុក)

ដូច្នេះ សេចក្តីសម្រេចត្រូវបានធ្វើឡើង។

<u>លទ្ធផលរបស់ប្រធានបទទី២ - ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និង លក្ខន្តិកៈក្រុមហ៊ុន ("M&A")</u>

| ល.រ. | កម្មវត្ថុ | ចំនួនភាគហ៊ុន (គាំទ្រ) | ភាគរយ (គាំទ្រ) | ចំនួនភាគហ៊ុន (ប្រឆាំង) | ភាគរយ (ប្រឆាំង) |
|---|---|---|---|---|---|
| ក | ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និង លក្ខន្តិកៈក្រុមហ៊ុន ("M&A") | ២៣.១៤៨.៧៤៩,០០ | ១០០% | ០ | ០ |

(ដោយការណ៍នៃការបោះឆ្នោតតាមប្រព័ន្ធឌីជីថល និងសន្និបាតតាមបែបនិម្មិតត្រូវបានថតទុក)

ដូច្នេះ សេចក្តីសម្រេចត្រូវបានធ្វើឡើង។

ភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២
ក្រុមហ៊ុន JS LAND PLC.

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ជេអេស ឡែន ភីអិលស៊ី
JS LAND PLC.
KINGDOM OF CAMBODIA